សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការបោកខោអាវ បាទ អញ្ចឹងជាទូទៅរៀងរាល់ថ្ងៃចុងសប្តាហ៍ បន្ទាប់ពីយើងមកពីរៀន បន្ទាប់ពីយើងសម្រាកពីការងារ ឬក៏បន្ទាប់ពីយើងសម្រាកពីការសិក្សា អញ្ចឹងយើងតែងតែមានខោអាវដើម្បីបោក ព្រោះថាយើងស្លៀកពាក់មួយអាទិត្យ អញ្ចឹងធ្វើឲ្យខោអាវយើងកខ្វក់ ដូច្នេះយើងត្រូវបោកខោអាវ។

ជាក់ស្តែងនៅក្នុងរូបភាពទី ១ យើងឃើញមានក្មេងប្រុសម្នាក់ បាទ ក្មេងប្រុសម្នាក់ អាយុគាត់ប្រហែលជា ១៨ ឆ្នាំ ដោយក្មេងប្រុសម្នាក់ហ្នឹង គាត់មានសក់ខ្លីពណ៌ខ្មៅ គាត់ពាក់អាវដៃខ្លីពណ៌ស បាទ ហើយគាត់ស្លៀកខោពណ៌សផងដែរ អញ្ចឹងក្មេងប្រុសម្នាក់ហ្នឹង កំពុងតែឈរច្រត់ចង្កេះ គាត់ឈរច្រត់ចង្កេះ ដោយភ្នែករបស់គាត់គឺសម្លឹងទៅមើលនៅក្នុងទូខោអាវរបស់គាត់ អញ្ចឹងយើងឃើញនៅពីមុខរបស់គាត់ នៅពីមុខគាត់ យើងឃើញមានទូខោអាវចំនួនមួយ បាទ ទូខោអាវចំនួនមួយ ហើយទូខោអាវនោះគឺកំពុងតែបើកទ្វារ អញ្ចឹងគាត់បើកទ្វារទូខោអាវ ដើម្បីរកមើលខោអាវនៅក្នុងទូ ប៉ុន្តែយើងឃើញថានៅក្នុងទូខោអាវនោះ គឺអត់មានខោអាវនោះទេ អញ្ចឹងទូខោអាវគឺអត់ឃើញមានខោអាវទេ គឺយើងឃើញតែមានស្ពាអាវ អញ្ចឹងស្ពាអាវគឺយើងប្រើសម្រាប់ព្យួរខោ ឬក៏ព្យួរអាវ ដើម្បីដាក់នៅក្នុងទូឲ្យមានសណ្តាប់ធ្នាប់ ពេលខ្លះខោអាវគឺ នៅពេលដែលយើងដាក់នៅក្នុងទូ គឺយើងបត់ ធ្វើការបត់វា ឬក៏ធ្វើការព្យួរវា អញ្ចឹងប្រសិនបើយើងមិនមានស្ពាអាវសម្រាប់ព្យួរនោះទេ យើងអាចបត់វា បាទ ក៏បានដែរ អញ្ចឹងយើងបត់វាដាក់ក្នុងទូ ទើបវាមានសណ្តាប់ធ្នាប់និងមិនប្រឡាក់ ព្រោះថាខោអាវថ្មីៗ ប្រសិនបើយើងដាក់នៅខាងក្រៅ វាអាចនឹងហុយដីប្រឡាក់ជាក់ជាពុំខាន អញ្ចឹងយើងយកវាទៅដាក់ក្នុងទូ ហើយបិទទ្វារឲ្យជិត អញ្ចឹងវាអត់ប្រឡាក់ទេនៅពេលដែលយើងបោកហើយ នៅក្នុងរូបភាពនេះគឺ គាត់អត់មានខោអាវនៅក្នុងទូទៀតទេ ព្រោះគាត់ប្រើប្រាស់ ឬក៏គាត់ស្លៀកពាក់ខោអាវរបស់គាត់អស់មួយអាទិត្យ អញ្ចឹងគាត់អត់ទាន់បានបោក ដូច្នេះអត់មានខោអាវនៅក្នុងទូខោអាវរបស់គាត់ទេ។

ចូលមកដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញបុរសដដែលនោះ គាត់បានដើរទៅរកកន្ត្រកខោអាវ បាទ កន្ត្រកខោអាវ។ អញ្ចឹងគាត់បានដើរដោយទៅរកកន្ត្រកខោអាវរបស់គាត់ដែលគាត់ដាក់ខោអាវដែលប្រឡាក់ យើងឃើញនៅក្នុងរូបភាពនេះ គាត់ដើរមករកតុមួយ បាទ តុមួយដែលនៅខាងមុខគាត់ តុនោះកម្ពស់ប្រហែលត្រឹមចង្កេះរបស់គាត់ អញ្ចឹងតុប្រហែលត្រឹមចង្កេះ ហើយនៅលើតុនោះ គឺមានកន្ត្រកមួយ បាទ កន្ត្រកហ្នឹងគឺគាត់ទុកនូវខោអាវជាច្រើននៅក្នុងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលជាខោអាវប្រឡាក់ៗ ដែលគាត់បានប្រើប្រាស់សម្រាប់រយៈពេលមួយអាទិត្យ អញ្ចឹងខោអាវ
យើងស្លៀកពាក់គឺយើងត្រូវផ្លាស់ប្តូរជារៀងរាល់ថ្ងៃ ដូចជានៅពេលដែលយើងទៅធ្វើការ
យើងមកពីធ្វើការវិញ យើងត្រូវផ្លាស់ខោអាវធ្វើការ ដោយស្លៀកពាក់សម្លៀកបំពាក់នៅផ្ទះ
បន្ទាប់មកនៅពេលដែលយើងចូលគេង យើងផ្លាស់សម្លៀកបំពាក់នោះ
ហើយយើងស្លៀកពាក់ខោអាវគេងម្តង អញ្ចឹងពេលខ្លះយើងអាចប្តូរបីកំប្លេក្នុងមួយថ្ងៃ
ឬក៏ពីរកំប្លេក្នុងមួយថ្ងៃ ព្រោះថានៅពេលដែលយើងស្លៀកខោអាវមួយកំប្លេៗយូរពេក
គឺវាធ្វើឲ្យប្រឡាក់ និងមានការកខ្វក់ ខោអាវនោះនឹងកខ្វក់ ដូច្នេះវាអាចនឹងមានមេរោគតោង
អញ្ចឹងយើងត្រូវផ្លាស់ប្តូរឲ្យបានញឹកញាប់ ដើម្បីរក្សាអនាម័យនៅក្នុងខ្លួន ជាក់ស្តែងបុរសម្នាក់នេះ
គាត់បានស្លៀកពាក់ចំនួនមួយអាទិត្យ ដូច្នេះគាត់ប្រើប្រាស់ខោអាវយ៉ាងច្រើន
យើងឃើញខោអាវគាត់[...]ពេញកន្ត្រកតែម្តង យើងឃើញនៅក្នុងនេះមានដូចជាខោ មានដូចជាអាវ
មានស្រោមជើង បាទ ដោយយើងឃើញស្រោមជើងនៅខាងលើគេ គឺស្រោមជើងពណ៌បៃតង
អញ្ចឹងគាត់ទុកខោអាវប្រឡាក់របស់គាត់នៅក្នុងកន្ត្រកមួយ ដើម្បីរក្សាសណ្តាប់ធ្នាប់
ព្រោះប្រសិនបើគាត់មិនទុកនៅក្នុងកន្ត្រកទេ ខោអាវរបស់គាត់នឹងរាយប៉ាយ អញ្ចឹងរាយប៉ាយ
អាចរាយប៉ាយពេញផ្ទះ ឬក៏រាយប៉ាយពេញបន្ទប់របស់គាត់ ធ្វើឲ្យគ្មានសណ្តាប់ធ្នាប់
ដែលធ្វើឲ្យបន្ទប់របស់គាត់រញ៉េរញ៉ៃ អញ្ចឹងគាត់ត្រូវដាក់មួយកន្លែង ឬក៏ដាក់នៅក្នុងកន្ត្រកមួយ
ដើម្បីឲ្យខោអាវរបស់គាត់មានសណ្តាប់ធ្នាប់។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ បុរសម្នាក់នោះបានយកកន្ត្រកខោអាវដែលប្រឡាក់
ហើយដើរទៅដល់កន្លែងបោកខោអាវ អញ្ចឹងគាត់បានយួរកន្ត្រកនោះ
ដោយយើងឃើញកន្ត្រកនោះមានកន្លែងចាប់សម្រាប់កាន់ពីរ បាទ មានកន្លែងសម្រាប់កាន់ពីរ
គឺនៅខាងឆ្វេងមួយ និងនៅខាងស្តាំមួយ ដោយកន្លែងសម្រាប់កាន់នោះគឺវាចោះជាប្រឡោះ
ដើម្បីឲ្យយើងងាយស្រួលដាក់ម្រាមដៃដើម្បីកាន់លើកនូវកន្ត្រកខោអាវនោះឡើង
អញ្ចឹងបុរសម្នាក់នោះ គាត់លើកកន្ត្រកខោអាវរបស់គាត់ដើរទៅរកកន្លែងបោកខោអាវ
ដោយយើងឃើញនៅខាងមុខរបស់គាត់ គឺយើងឃើញមានម៉ាស៊ីនបោកខោអាវចំនួនមួយ បាទ
ម៉ាស៊ីនបោកខោអាវ ហើយនៅលើធ្នើរ នៅលើម៉ាស៊ីនបោកខោអាវនោះយើងឃើញមានធ្នើរមួយ
អញ្ចឹងធ្នើរនោះ យើងឃើញមានដូចជាដាក់សាប៊ូ កំប៉ុងសាប៊ូ ឬក៏កំប៉ុងទឹកក្រអូប
ឬក៏កញ្ចប់សាប៊ូម្សៅជាដើម។ អញ្ចឹងយើងប្រើប្រាស់សាប៊ូដើម្បីបោកជាមួយនឹងខោអាវ
ហើយជាទូទៅនៅប្រទេសកម្ពុជា គឺភាគច្រើនគឺយើងអត់សូវប្រើម៉ាស៊ីនបោកខោអាវនោះទេ
ជាពិសេសនៅតាមទីជនបទ ព្រោះថានៅតាមទីជនបទ
គឺយើងអត់ទាន់មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ អញ្ចឹងគាត់បោកខោអាវដោយប្រើដៃរបស់គាត់
អញ្ចឹងគាត់បោកខោអាវនឹងដៃ ដោយគាត់យកដៃរបស់គាត់ញីខោអាវដែលប្រឡាក់ ឬក៏ប្រើប្រាស

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីដុសសម្អាតនៃស្នាមប្រឡាក់នានា ដោយគាត់ពុំមានម៉ាស៊ីនបោកខោអាវដើម្បីប្រើប្រាស់នោះទេ
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថាបុរសម្នាក់នេះ ប្រហែលជាគាត់រស់នៅទីក្រុង
ដូច្នេះហើយទើបគាត់មានម៉ាស៊ីនបោកខោអាវ ព្រោះម៉ាស៊ីនបោកខោអាវគឺត្រូវការទឹក ទឹកម៉ាស៊ីន
ជាមួយនឹងភ្លើងអគ្គិសនី ទើបអាចធ្វើឲ្យវាដំណើរការបាន អញ្ចឹងនៅប្រទេសកម្ពុជា
នៅទីជនបទគឺយើងអត់សូវមានទឹកម៉ាស៊ីនឬក៏អគ្គិសនីទេ
ដូច្នេះយើងពុំសូវមានម៉ាស៊ីនបោកខោអាវសម្រាប់ប្រើប្រាស់នោះទេ។

បន្ទាប់មកទៀតចូលមកដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញបុរសម្នាក់នោះ
គាត់កំពុងតែរំលែកខោអាវចេញជាពីរ បាទ គាត់កំពុងតែរំលែកខោអាវ
ដោយគាត់បែងចែកខោអាវនោះ ដោយគាត់យកអាវសដាក់មួយឡែក និងអាវពណ៌ដាក់មួយឡែក
អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គាត់កំពុងតែដាក់កន្ត្រកខោអាវនៅលើតុមួយ
ដែលមានកម្ពស់ត្រឹមចង្កេះរបស់គាត់ បន្ទាប់មកគាត់យកដៃរបស់គាត់ចាប់រំលែកខោអាវ
ដោយគាត់រើសយកពណ៌សដាក់ម្ខាងនិងខោអាវពណ៌ដាក់ម្ខាង អញ្ចឹងយើងឃើញរូបនេះ
គឺគាត់យកខោអាវសដាក់ទៅខាងឆ្វេងដៃរបស់គាត់ ចំណែកឯខាងខោអាវពណ៌
គឺនៅខាងស្តាំដៃរបស់គាត់
គាត់ធ្វើបែបនេះគឺដើម្បីកុំឲ្យមានការច្រឡូកច្រឡំគ្នារវាងអាវសនិងអាវពណ៌
ព្រោះថាប្រសិនបើយើងបោកខោអាវអាវពណ៌ជាមួយនឹងអាវសច្របូកច្របល់គ្នា
វាអាចនឹងប្រឡាក់អាវស ព្រោះពេលខ្លះអាវពណ៌វាអាចនឹងចេញពណ៌
ដូចជាយើងពាក់ខោអាវពណ៌ខៀវ ពេល[ដែល]យើងបោក គឺវាអាចចេញពណ៌ដែលគេជ្រលក់
នៅពេលដែលជ្រលក់ថ្នាំអត់ល្អ គឺវាចេញពណ៌នៅពេលដែលយើងបោក
អញ្ចឹងប្រសិនបើយើងបោកជាមួយអាវស ពណ៌នោះអាចនឹងចេញមកប្រឡាក់អាវសជាក់ជាមិនខាន
ដូច្នេះហើយបុរសម្នាក់នោះ គាត់ក៏បានរំលែកខោអាវចេញជាពីរចំណែក ដោយយកអាវសបោកផ្សេង
និងខោអាវពណ៌បោកផ្សេង។

ចូលមកដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញមានរូបចំនួនពីរ ដោយនៅក្នុងរូបភាពទី ៥
នេះ គឺនៅរូបនៅខាងឆ្វេងដៃ គឺយើងឃើញបុរសម្នាក់នោះ
គាត់កំពុងតែបើកគម្របម៉ាស៊ីនបោកខោអាវ អញ្ចឹងជាទូទៅម៉ាស៊ីនបោកខោអាវគឺមានគម្របមួយ
ដើម្បីទុកបិទបើកនៅពេលដែលយើងដំណើរការម៉ាស៊ីន ព្រោះថាប្រសិនបើអត់មានគម្របនោះទេ
វាអាចខ្ទាតទឹកចេញមកក្រៅ ឬក៏ខ្ទាតខោអាវចេញមកក្រៅ
ហើយមួយទៀតប្រសិនបើយើងអត់បិទគម្រប អត់មានគម្រប នៅពេលដែលម៉ាស៊ីនកំពុងដំណើរការ
វាអាចនឹងមានគ្រោះថ្នាក់ដល់យើង ប្រសិនបើយើងច្រឡំលូកដៃចូលទៅក្នុងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះម៉ាស៊ីនបោកខោអាវតែងតែមានគម្របមួយ ដើម្បីទុកបើកនិងបិទ
នៅពេលដែលម៉ាស៊ីនដំណើរការ ឬក៏បន្ទាប់ពីយើងប្រើប្រាស់រួច អញ្ចឹងហើយនៅក្នុងរូបភាពនេះ
គឺគាត់កំពុងតែចង់ប្រើម៉ាស៊ីនបោកខោអាវ ដូច្នេះគាត់ត្រូវបើកគម្របម៉ាស៊ីនបោកខោអាវសិន
មុននឹងដាក់ខោអាវចូល បន្ទាប់មកយើងឃើញនៅរូបភាពទីខាងស្ដាំ នៅក្នុងរូបភាពខាងស្ដាំដៃ
នៅក្នុងរូបភាពទី ៥ ដដែលនេះ យើងឃើញ បន្ទាប់ពីគាត់បើកគម្របម៉ាស៊ីនបោកខោអាវរួចហើយ
បុរសម្នាក់នោះ គាត់ក៏បានយកខោអាវពណ៌របស់គាត់ ដែលបានរំលែកអម្បាញ់មិញ
ដាក់ចូលទៅក្នុងម៉ាស៊ីន អញ្ចឹងគាត់យកខោអាវពណ៌ ដើម្បីរំលែកនោះ ដែលបានរំលែកនោះ
ដាក់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវរបស់គាត់ដើម្បីបោក។

ចូលមកដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦
បន្ទាប់ពីគាត់ដាក់ខោអាវពណ៌របស់គាត់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវរួចហើយ បុរសម្នាក់នោះ
គាត់ក៏បានចាក់ទឹកសាប៊ូ បាទ គាត់ចាក់ទឹកសាប៊ូចូលទៅក្នុងកែវមួយ
អញ្ចឹងយើងបោកខោអាវជាមួយនឹងទឹកសាប៊ូឬក៏សាប៊ូម្សៅ ដោយជាទូទៅសាប៊ូម្សៅ
នៅក្នុងប្រទេសកម្ពុជាគេចូលចិត្តប្រើសម្រាប់បោកខោអាវជាង ព្រោះវាមានតម្លៃសមរម្យ
ដែលយើងអាចប្រើប្រាស់បានគ្រប់គ្នា អញ្ចឹងនៅក្នុងប្រទេសកម្ពុជា
យើងបោកខោអាវជាមួយនឹងសាប៊ូម្សៅ ប៉ុន្តែនៅក្នុងរូបភាពនេះ គឺគាត់ប្រើប្រាស់សាប៊ូទឹក
អញ្ចឹងសាប៊ូទឹកឬក៏សាប៊ូរាវហ្នឹងគឺមានគុណភាពដូចគ្នាជាមួយនឹងសាប៊ូម្សៅ
ប៉ុន្តែគ្រាន់តែថាសាប៊ូទឹកគឺ គឺឆាប់រលាយនៅក្នុងទឹកជាង ដោយសារតែវាជាទឹកស្រាប់
អញ្ចឹងហើយនៅក្នុងរូបភាពនេះ នៅពេលដែលយើងបោកខោអាវជាមួយនឹងម៉ាស៊ីន
យើងត្រូវប្រើសាប៊ូទឹក ដើម្បីបោកជាមួយនឹងខោអាវ
ដើម្បីលាងជម្រះស្នាមប្រឡាក់ចេញពីខោអាវរបស់យើង។

ចូលមកដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា
បន្ទាប់ពីគាត់ចាក់ទឹកសាប៊ូចូលទៅក្នុងកែវមួយហើយ គាត់ក៏បានយកកែវនោះ
ដើម្បីចាក់ទឹកសាប៊ូចូលទៅក្នុងម៉ាស៊ីនដែលគាត់បានដាក់ខោអាវចូល អញ្ចឹងម៉ាស៊ីនបោកខោអាវ
បន្ទាប់ពីគាត់ដាក់ខោអាវដែលប្រឡាក់ចូលទៅក្នុងម៉ាស៊ីនហើយ
គាត់ក៏បានបន្ថែមសាប៊ូចូលទៅក្នុងម៉ាស៊ីននោះទៀត ដើម្បីឲ្យវាលាងជម្រះខោអាវឲ្យបានស្អាត
ព្រោះប្រសិនបើយើងបោកមិនប្រើប្រាស់សាប៊ូនោះទេ គឺយើងបោកអត់ស្អាតនោះទេ
ព្រោះស្នាមប្រឡាក់គឺនៅកាន់ជាប់នឹងសាច់ក្រណាត់តែម្ដង ដូច្នេះយើងត្រូវតែប្រើប្រាស់សាប៊ូ
ដើម្បីឲ្យសាប៊ូទៅលាងជម្រះខោអាវរបស់យើងឲ្យបានកាន់តែស្អាត នៅក្នុងរូបភាពទី ៧ ដដែលនេះ
នៅខាងស្ដាំដៃ គឺយើងឃើញរូបភាពនៅខាងស្ដាំដៃនេះ គឺបុរសម្នាក់នោះ បន្ទាប់ពីគាត់ដាក់ខោអាវ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ដាក់សាប៊ូចូលរួចហើយ បុរសម្នាក់នោះ គាត់ក៏បានបិទគម្របម៉ាស៊ីនមកវិញ
អញ្ចឹងបន្ទាប់ពីយើងដាក់ខោអាវចូលរួចហើយ ហើយនិងដាក់សាប៊ូចូល
យើងត្រូវតែបិទគម្របម៉ាស៊ីនដើម្បីដំណើរការម៉ាស៊ីន ប្រសិនបើយើងមិនបិទគម្របនោះទេ
ម៉ាស៊ីនបោកខោអាវក៏មិនអាចដំណើរការបានដែរ ដូច្នេះគាត់ត្រូវតែបិទគម្រប
ដើម្បីឲ្យម៉ាស៊ីនដំណើរការបាន។

បន្ទាប់ពីគាត់បិទគម្របម៉ាស៊ីនហើយ គាត់ក៏បានចុចនូវគ្រាប់ចុចនៅលើម៉ាស៊ីន បាទ
ឬក៏ចុចប៊ូតុងនៅលើម៉ាស៊ីន ដើម្បីឲ្យម៉ាស៊ីនដំណើរការ អញ្ចឹងក្នុងការបោកខោអាវ
ម៉ាស៊ីនបោកខោអាវមានកម្មវិធីជាច្រើនសម្រាប់បោកខោអាវផ្សេងៗគ្នា ដូចជាសម្រាប់បោកភួយ
សម្រាប់បោកខោអាវកីឡា សម្រាប់បោកខោអាវធម្មតា សម្រាប់បោកសរសៃសូត្រជាដើម
អញ្ចឹងប្រសិនបើយើងជាខោអាវធម្មតាទេ យើងចុចលើគ្រាប់ចុច
ឬក៏ចុចលើប៊ូតុងសម្រាប់បោកខោអាវធម្មតា
ដូច្នេះម៉ាស៊ីននឹងដំណើរការបោកបញ្ចេញកម្លាំងម៉ាស៊ីនធម្មតាដែរ ដោយវាមិនប្រឹងខ្លាំងពេក
ឬក៏វាមិនប្រឹងខ្សោយពេក អញ្ចឹងធ្វើឲ្យម៉ាស៊ីនរបស់យើងមិនងាយខូច
ប៉ុន្តែប្រសិនបើយើងបោកខោអាវធម្មតា ហើយយើងចុចកម្មវិធីឲ្យវាដំណើរការលើការបោកភួយ
អញ្ចឹងម៉ាស៊ីនរបស់យើងធ្វើការខ្លាំង ដូច្នេះវាអាចធ្វើឲ្យឆាប់ខូច
អញ្ចឹងយើងត្រូវកំណត់កម្មវិធីឲ្យម៉ាស៊ីនដំណើរការទៅតាមប្រភេទខោអាវដែលយើងចង់បោក
ដើម្បីឲ្យម៉ាស៊ីនមិនងាយខូចនិងប្រើប្រាស់បានយូរ ជាក់ស្តែងនៅក្នុងរូបភាពនេះ បុរសម្នាក់នោះ
គាត់បានបោកខោអាវធម្មតា ដូច្នេះហើយបុរសម្នាក់នោះ
ក៏គាត់ជ្រើសរើសកម្មវិធីឲ្យម៉ាស៊ីនបោកខោអាវធម្មតា ហើយក៏គាត់ចុចប៊ូតុង start ឬក៏ប៊ូតុងចាប់ផ្តើម
អញ្ចឹងនៅពេលដែលគាត់ចុចប៊ូតុងចាប់ផ្តើមនោះហើយ
ម៉ាស៊ីននឹងចាប់ផ្តើមដំណើរការបោកខោអាវរបស់គាត់តែម្តង។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្ទាប់ពីគាត់ចុចប៊ូតុងឲ្យ[ទៅ]ម៉ាស៊ីនដំណើរការរួចហើយ
ម៉ាស៊ីនក៏បានលោតជាសញ្ញាមួយមកប្រាប់គាត់ ដើម្បីឲ្យគាត់រង់ចាំរយៈពេល ៤៥ នាទី
អញ្ចឹងដោយសារតែខោអាវគាត់ច្រើន បាទ ដោយសារតែខោអាវគាត់ច្រើន
អញ្ចឹងគាត់ត្រូវការរង់ចាំរយៈពេលយូរដែរ គឺរយៈពេល ៤៥ នាទី ក្នុងការរង់ចាំនេះ
គឺអាស្រ័យទៅលើខោអាវរបស់យើង អញ្ចឹងប្រសិនបើខោអាវតិច សម្លៀកបំពាក់របស់យើងតិច
នោះយើងរង់ចាំរយៈពេលខ្លី ដូចជា ២០ នាទី ឬក៏ ៣០ នាទីជាដើម
ប៉ុន្តែប្រសិនបើយើងមានខោអាវច្រើន អញ្ចឹងយើងត្រូវរង់ចាំរយៈពេលយូរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះថាម៉ាស៊ីននឹងធ្វើការយូរដែរ ដើម្បីសម្អាតខោអាវយើងឲ្យបានស្អាត ដូច្នេះហើយ គាត់នៅក្នុងរូបភាពនេះ គាត់ត្រូវរង់ចាំរយៈពេល ៤៥ នាទីដើម្បីបោកខោអាវរបស់គាត់។

នៅក្នុងរូបភាពទី ១០ ចូលនៅក្នុងរូបភាពទី ១០ យើងឃើញថា បុរសម្នាក់នោះ
គាត់ក៏បានកំពុងតែយកខោអាវចេញពីម៉ាស៊ីនវិញ អញ្ចឹងបានន័យថា
ម៉ាស៊ីននោះបានដំណើរការបោកខោអាវរួចរាល់ហើយ បានន័យថាកន្លងទៅ ៤៥ នាទីហើយ
អញ្ចឹងបន្ទាប់ពីគាត់រង់ចាំរយៈពេល ៤៥ នាទី
គាត់ក៏បានមកប្រមូលខោអាវចេញពីម៉ាស៊ីនបោកខោអាវគាត់ ដូច្នេះនៅក្នុងរូបភាពនេះយើងឃើញថា
គាត់បានបើកគម្របម៉ាស៊ីនឡើង បាទ គាត់បានបើកគម្របម៉ាស៊ីនឡើង
រួចហើយប្រមូលខោអាវពណ៌របស់គាត់ដាក់ចូលទៅក្នុងកន្ត្រកមួយ
អញ្ចឹងគាត់យកកន្ត្រកដែលគាត់ដាក់សម្លៀកបំពាក់ប្រឡាក់នោះ គឺគាត់យកមកវិញ
រួចហើយគាត់ប្រមូលសម្លៀកបំពាក់ដែលគាត់បោកនៅក្នុងម៉ាស៊ីនរួចរាល់នោះ
ដាក់ទៅក្នុងកន្ត្រកនោះ ដើម្បីយកទៅហាល។

អញ្ចឹងគាត់បានប្រមូលដាក់ទៅក្នុងកន្ត្រកមួយ បន្ទាប់មកទៀតនៅក្នុងរូបភាពទី ១១
នៅក្នុងរូបភាពទី ១១ យើងឃើញថា បន្ទាប់ពីបុរសម្នាក់នោះ គាត់បានប្រមូលខោអាវ ស្រោមជើង
ជាមួយនឹងខោអាវពណ៌ផ្សេងៗ ដូចជាអាវយឺត អាវនៅផ្ទះនិងអាវគេងយប់របស់គាត់នោះ
ដាក់ចូលក្នុងកន្ត្រកហើយ បុរសម្នាក់នោះក៏បានលើកកន្ត្រកទាំងនោះ លើកកន្ត្រកខោអាវទាំងនោះ
មកដាក់នៅខាងក្រៅដើម្បីហាល អញ្ចឹងយើង នៅក្នុងរូបភាពនេះ
យើងឃើញថាគាត់កំពុងតែលើកកន្ត្រក ហើយដើរមកកាន់ស្នួហាលខោអាវមួយ អញ្ចឹងប្រដាប់
ឬក៏ឧបករណ៍សម្រាប់ហាលខោអាវ យើងហៅថាស្នួ អញ្ចឹងស្នួហាលខោអាវ
គឺធ្វើឡើងសម្រាប់ឲ្យយើងហាលខោអាវបន្ទាប់ពីយើងបោករួច ហើយយើងហាលខោអាវ
គឺត្រូវហាលនៅក្រោមពន្លឺព្រះអាទិត្យ ដើម្បីឲ្យវាឆាប់ស្ងួត ជាក់ស្តែងនៅក្នុងរូបភាពនេះ
បុរសម្នាក់នោះគាត់បានយួរខោអាវរបស់គាត់ដើម្បីចេញក្រៅផ្ទះ អញ្ចឹងជាធម្មតាយើងហាលខោអាវ
គឺយើងហាលនៅខាងក្រៅផ្ទះ នៅខាងមុខផ្ទះ ឬក៏នៅក្នុងដីដែលនៅខាងក្រៅផ្ទះរបស់យើង
ព្រោះថានៅខាងក្រៅទើបមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ ដើម្បីធ្វើឲ្យខោអាវឆាប់ស្ងួត
និងមានខ្យល់អាកាស ព្រោះថាខោអាវនឹងស្ងួតនៅពេលដែលវាត្រូវខ្យល់និងត្រូវពន្លឺព្រះអាទិត្យ
អញ្ចឹងនៅក្នុងរូបភាពនេះ គាត់កំពុងតែយកខោអាវមកដើម្បីហាល
ព្រោះថាខោអាវដែលបោកចេញពីម៉ាស៊ីនហើយ គឺវានៅសើមនៅឡើយ គឺមាន គឺនៅមានទទឹក
គឺបានន័យថាខោអាវនៅទទឹក ឬក៏នៅសើម ដូច្នេះគាត់ត្រូវហាលខោអាវសិន
មុននឹងគាត់អាចប្រើប្រាស់ខោអាវនោះបាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ១២ ចូលមកដល់រូបភាពទី ១២ យើងឃើញថា គាត់បានយកខោអាវដែលគាត់បោករួចនោះ មកហាលនៅលើស្នូទាំងអស់ អញ្ចឹងយើងឃើញស្នូនោះ គឺជាស្នូដែក បាទ ជាស្នូដែក ហើយ[បាន] គាត់បានយកខោអាវរបស់គាត់មកព្យួរពីលើស្នូនោះ ម្ដងមួយៗរហូតដល់តែអស់ អញ្ចឹងពេលខ្លះគឺនៅទីក្រុង ឬក៏នៅកន្លែងដែលទីប្រជុំជននានា គឺយើងប្រើប្រាស់ស្នូដែកមួយដែលយើងទិញ ដែលស្នូនោះគឺបង្កលក្ខណៈងាយស្រួល ដើម្បីឲ្យយើងហាលខោអាវ ប៉ុន្តែប្រសិនបើយើងមិនមានស្នូដែកទេ នៅក្នុងប្រទេសកម្ពុជាជាទូទៅគឺយើងចងខ្សែ អញ្ចឹងយើងអាចចងខ្សែពីរបងផ្ទះមកដល់សសរផ្ទះ ឬក៏ចងខ្សែពីរបងម្ខាងទៅរបងម្ខាងទៀត បាទ ដើម្បីចងខ្សែហើយដើម្បីហាលខោអាវនៅលើខ្សែនោះ អញ្ចឹងទោះបីជាចងខ្សែ ក៏យើងហៅថាស្នូហាលខោអាវដែរ ដូចគ្នានឹងស្នូហាលខោអាវដែកដែលយើងទិញពីផ្សារផងដែរ អញ្ចឹងជាទូទៅនៅក្នុងប្រទេសកម្ពុជា គឺយើងប្រើប្រាស់ស្នូហាលខោអាវដែលជាខ្សែ ដែលយើងចងទៅលើរបង ច្រើនជាងការហាលខោអាវទៅលើស្នូដែក។

បន្ទាប់មកនៅក្នុងរូបភាពទី ១៣ ចូលដល់រូបភាពទី ១៣ បន្ទាប់ពីគាត់ហាលខោអាវហើយ បុរសម្នាក់នោះ គាត់ក៏បានចូលមកក្នុងផ្ទះរបស់គាត់វិញ បាទ ព្រោះថាគាត់ហាលខោអាវនៅខាងក្រៅផ្ទះ [នៅ]ហាលក្ដៅ អញ្ចឹងគាត់ត្រូវចូលមកក្នុងផ្ទះរបស់គាត់វិញ ដើម្បីរង់ចាំឲ្យខោអាវគាត់ស្ងួត ដូច្នេះប្រសិនបើគាត់រង់ចាំនៅខាងក្រៅ គឺមានរយៈពេលយូរហើយក្ដៅ អញ្ចឹងគាត់អាចនឹងក្ដៅ ឬក៏អាចធ្វើឲ្យគាត់មិនស្រួលនៅក្នុងខ្លួន ព្រោះថាគាត់ឈរហាលក្ដៅ ដូច្នេះគាត់ត្រូវចូលមកក្នុងផ្ទះ ដើម្បីរកម្លប់ ហើយអង្គុយលេងចុចទូរស័ព្ទ ដើម្បីរង់ចាំរហូតដល់ខោអាវរបស់គាត់ស្ងួតវិញ អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថា គាត់កំពុងតែអង្គុយនៅលើសាឡុងមួយ បាទ អញ្ចឹងគាត់អង្គុយនៅលើសាឡុង ដោយដៃរបស់គាត់ដាក់នៅលើបង្កាន់ដៃសាឡុង ហើយខ្នងរបស់គាត់ផ្អែកទៅលើបង្អែករបស់សាឡុងនោះ បាទ ហើយដៃម្ខាងទៀត គាត់កំពុងតែចុចទូរស័ព្ទ ដោយភ្នែករបស់គាត់មើលទៅក្នុងទូរស័ព្ទ នៅក្នុងនេះគាត់អាចជាលេងហ្វេសប៊ុក ឬក៏គាត់អាចឆាតជាមួយនឹងមិត្តភក្តិរបស់គាត់ ឬគាត់អាចផ្ញើសារទៅលេងមិត្តភក្តិរបស់គាត់ជាដើម ឬក៏គាត់កំពុងតែលេងហ្គេមទូរស័ព្ទជាដើម ដូច្នេះគាត់អង្គុយលេងហ្គេមទូរស័ព្ទ ឬក៏គាត់លេងទូរស័ព្ទរបស់គាត់ដោយអង្គុយលើសាឡុង ដើម្បីរង់ចាំឲ្យខោអាវរបស់គាត់ស្ងួត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មករូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា
បន្ទាប់ពីគាត់រង់ចាំរយៈពេលយូរមកហើយ ខោអាវគាត់ក៏ចាប់ផ្ដើមស្ងួត
អញ្ចឹងគាត់ក៏បានទៅសាខោអាវយកមកវិញ អញ្ចឹងយើងឃើញរូបភាពនេះ
គឺគាត់ដើរទៅរកស្នូខោអាវរបស់គាត់វិញ ដោយយើងឃើញថា ស្នូខោអាវរបស់គាត់គឺក្ដៅ
ដោយយើងឃើញក្នុងរូបភាពនេះគឺមានផ្សែង គឺគេធ្វើដូចជាផ្សែង បាទ ហុយចេញពីស្នូហាលខោអាវ
ប៉ុន្តែវាមិនមែនជាផ្សែងនោះទេ គឺរូបភាពនេះគឺជារលកកម្ដៅ អញ្ចឹងយើងហៅថារលកកម្ដៅ
ដែលចេញពីដែក អញ្ចឹងដែក នៅពេលដែលដាក់ហាលថ្ងៃ គឺវាក្ដៅ ដូច្នេះវានឹងមានរលកកម្ដៅ
ដើម្បីភាយចេញមកខាងក្រៅ អញ្ចឹងខោអាវដែលយើងហាលថ្ងៃគឺឆាប់ស្ងួត
ដូច្នេះគាត់ក៏ទៅសាខោអាវរបស់គាត់ដែលហាលរួចហើយ ហើយប្រមូលយកមកទុកវិញ
នៅក្នុងរូបភាពនេះយើងឃើញថា យើងឃើញដៃរបស់គាត់មួយចំហៀង ឬក៏មួយខាង
ដៃរបស់គាត់ម្ខាងកំពុងតែកងខោអាវ បាទ អញ្ចឹងយើងយកខោអាវមកដាក់លើដើមដៃរបស់យើង
ហើយដាក់ភ្ជាប់ទៅនឹងខ្លួន ដោយដាក់ខោអាវនៅលើដៃ ដូច្នេះយើងហៅថាកង
អញ្ចឹងគាត់កំពុងតែកងខោអាវរបស់គាត់
ហើយដៃម្ខាងទៀតកំពុងតែប្រមូលខោអាវយកពីស្នូហាលអាវ ដើម្បីយកទៅទុក។

បន្ទាប់មកនៅក្នុងរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា
បន្ទាប់ពីគាត់សាខោអាវរបស់គាត់ដែលហាលរួចនោះរួចហើយ គាត់ក៏យកខោអាវនោះមកក្នុងផ្ទះ
រួចហើយដាក់នៅលើតុមួយ បន្ទាប់មកគាត់ក៏បានបត់ខោអាវ អញ្ចឹងបន្ទាប់ពីគាត់បោកខោអាវហើយ
គាត់ហាល បន្ទាប់ពីគាត់ហាលហើយ គាត់សាខោអាវនោះ ដើម្បីយកមកបត់ទុក
អញ្ចឹងប្រសិនបើយើងអត់បត់ខោអាវទុកទេ ខោអាវរបស់យើងនឹងមិនមានសណ្ដាប់ធ្នាប់
ហើយវាអាចធ្វើឲ្យប្រឡាក់ខោអាវយើងផងដែរ ដូច្នេះដើម្បីរក្សាសណ្ដាប់ធ្នាប់ខោអាវរបស់យើង
យើងត្រូវបត់ខោអាវនោះឲ្យមានសណ្ដាប់ធ្នាប់ល្អ ហើយយកទៅទុកនៅក្នុងទូ
ឬក៏ទុកនៅក្នុងកន្លែងណាមួយដែលស្អាត ដូច្នេះខោអាវរបស់យើងនឹងមិនប្រឡាក់ទៀតនោះទេ
ជាក់ស្ដែងនៅក្នុងរូបភាពនេះយើងឃើញថា នៅខាងស្ដាំដៃរបស់បុរសនោះ
គឺមានខោអាវជាច្រើនដែលមិនទាន់បត់
ដែលជាខោអាវដែលគាត់ទើបតែសាមកពីស្នូហាលខោអាវរបស់គាត់អម្បាញ់មិញ
អញ្ចឹងគាត់សាហើយគាត់យកមកទុកលើតុមួយ បន្ទាប់មកគាត់កំពុងតែបត់ខោអាវ ដែលគាត់
គាត់កំពុងតែបត់អាវដែលមានពណ៌ ពណ៌ស្វាយ បាទ គាត់កំពុងតែបត់ខោអាវដែលមានពណ៌ស្វាយ
ហើយនៅជិតគាត់ដែលនៅខាងឆ្វេងដៃរបស់គាត់នោះ
យើងឃើញមានខោអាវដែលគាត់បត់ហើយជាច្រើន ដែលមានពណ៌ក្រហម ពណ៌ខៀវ
ពណ៌លឿងជាដើម អញ្ចឹងគាត់ហាលខោអាវហើយគាត់សាយកមកដើម្បីបត់ទុក ដែលខោអាវខ្លះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពេលខ្លះ ដូចជាអាវយឺត ឬក៏ខោខោវប៊យជាដើម យើងមិនចាំបាច់ព្យួរនោះទេ
អញ្ចឹងយើងគ្រាន់តែបត់វាជាការស្រេចដើម្បីឲ្យមានសណ្ដាប់ធ្នាប់
ព្រោះខោអាវទាំងនេះគឺនៅពេលដែលយើងយកមកពាក់ គឺវាមិនខ្ទេចនោះទេ
ដោយសារតែវាជាអាវយឺត ហើយនឹងជាខោខោវប៊យ ដូច្នេះគឺយើងអាចពាក់វាភ្លាមៗតែម្ដង
ដែលយើងមិនត្រូវការអ៊ុតនោះទេ។

បន្ទាប់មកទៀតនៅក្នុងរូបភាពចុងក្រោយ រូបភាពទី ១៦ រូបភាពទី ១៦ យើងឃើញថា
បន្ទាប់ពីគាត់បត់ខោអាវរួចរាល់ហើយ បាទ ខោអាវយឺតរបស់គាត់ អាវយឺតខោខោវប៊យ យើងត្រូវបត់
បន្ទាប់ពីគាត់បត់អាវយឺតរួចរាល់ហើយ អាវផ្សេងទៀត ដូចជាអាវឯកសណ្ឋានទៅរៀន
ឯកសណ្ឋានទៅសាលា ឬក៏ឯកសណ្ឋានដែលគាត់ពាក់ទៅធ្វើការជាដើម អញ្ចឹងខោអាវទាំងនោះ
យើងមិនអាចបត់បានទេ ព្រោះថានៅពេលដែលយើងបត់ វាអាចឲ្យខ្ទេចសាច់ក្រណាត់
អញ្ចឹងយើងពិបាកនៅក្នុងការពាក់ដើម្បីទៅធ្វើការ ដូច្នេះហើយខោអាវឯកសណ្ឋានសាលា
ឬក៏ឯកសណ្ឋានដើម្បីទៅធ្វើការ យើងត្រូវព្យួរវាឲ្យមានសណ្ដាប់ធ្នាប់ គឺយើងមិនបត់នោះទេ
អញ្ចឹងយើងត្រូវព្យួរ ដូច្នេះនៅក្នុងរូបភាពនេះ យើងឃើញបុរសនោះ គាត់បានយកខោអាវមួយចំនួន
ដែលជាអាវធ្វើការរបស់គាត់ ទៅព្យួរនៅក្នុងទូវិញ ដោយយើងឃើញគាត់បើកទ្វារទូម្ដងទៀត
ហើយយកស្មាអាវរបស់គាត់ ស្មាអាវដែលនៅក្នុងទូនោះ មកព្យួរជាមួយនឹងអាវ
ដូច្នេះគាត់យកអាវរបស់គាត់ទៅព្យួរនឹងស្មាអាវ រួចហើយយកខោអាវដែលព្យួររួចនោះ
ទៅដាក់នៅក្នុងទូ អញ្ចឹងដាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញថា
មានអាវចំនួនពីរនៅក្នុងទូរបស់គាត់ ដែលគាត់បានព្យួររួចហើយ ដូចជាអាវនោះ ពណ៌ ដូចជាស្វាយ
ហើយនិងអាវពណ៌ខៀវ អញ្ចឹងនៅក្នុងដៃរបស់គាត់ គឺមានអាវពណ៌លឿងមួយទៀត
ដែលជាអាវដៃវែង អញ្ចឹងគាត់កំពុងតែយកអាវដៃវែងពណ៌លឿងនោះ ទៅព្យួរនៅក្នុងទូមួយទៀត
ដើម្បីទុកឲ្យវាមានសណ្ដាប់ធ្នាប់ និងចៀសផុតពីការប្រឡាក់
ហើយគាត់ត្រៀមសម្រាប់ការស្លៀកពាក់ទៅធ្វើការនៅថ្ងៃស្អែកទៀត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.